ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមេសា ឆ្នាំ២០១៩

*នៅក្នុងខែមេសា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖*

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

*-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និង ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក*

*-អញ្ជើញទទួលព្រះរាជដំណើរ* ***ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង****សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងនិវត្តន៍ពីសាធារណរដ្ឋប្រជាមានិតចិនមកកាន់មាតុប្រទេសវិញ*

*-ទទួលសារតាំងពីលោកជំទាវ* Ana Lucy Gentil Cabral Petersen *និងឯកឧត្តម* Gunnar Snorri Gunnarsson *ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋសហព័ន្ធប្រេស៊ីល និងសាធារណរដ្ឋអ៊ីស្លង់*

*-អនុញ្ញាតជូនលោក* Chen Qiufa *លេខាបក្សខេត្ត* Liao Ning *នៃសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរ*

*-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផល និងសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងក្រុងច្បារមន ខេត្តកំពង់ស្ពឺ*

*-អញ្ជើញនាំយកបច្ច័យ ទេយ្យទាន និងគ្រឿងបរិក្ខារផ្សេងៗ ថ្វាយសម្តេចព្រះមហាសុមេធាធិបតី* ***នន្ទ ង៉ែត*** *សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ*

-អញ្ជើញចុះពិនិត្យការដ្ឋានកំពុងសាងសង់ សមិទ្ធផលថ្មីៗក្នុងវត្តនាគវ័ន ព្រមទាំងប្រគេនបច្ច័យចំនួន៣០០០០ដុល្លារសហរដ្ឋអាមេរិក ដល់ព្រះគ្រូចៅអធិការវត្តដើម្បីកសាងបន្តទៀត នៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

-អញ្ជើញប្រារព្ធពិធីសូត្រមន្តចម្រើនសិរីសួស្តីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ និងបង្សុកូល ដើម្បីឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធ បុព្វ-ការីជន និងញាតិកាទាំង៧សន្តានរបស់សម្តេច និងក្រុមគ្រួសារនៅគេហដ្ឋានក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីបូជាសពឯកឧត្តម **ជុំ វង** លេខាធិការគណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាននៃព្រឹទ្ធសភា និងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នៅក្នុងភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៥៦ច្បាប់ ព្រះរាជសារព្រះប្រទានសិទ្ធិចំនួន២៣ច្បាប់ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៣៨សំណើ ពីរដ្ឋសភាចំនួន០៥សំណើ ពីប្រធានស្តីទីព្រឹទ្ធសភាចំនួន០១សំណើ ចុះហត្ថលេខាលើឯកសារផ្សេងចំនួន០២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់ ។

**១.២-ឯកឧត្តម ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឱ្យគណៈប្រតិភូសភាសហព័ន្ធវ៉ាល់ឡូនី-ព្រុចសែល ដឹកនាំដោយឯកឧត្តម **ហ្វីលីព កូរ៉ាដ** (Philippe Courard) ប្រធានសភា ចូលជួបសវនាការ

-អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ជាកិត្តិយស ក្នុងស្មារតីមិត្តភាព និងសាមគ្គីភាពដ៏ជិតស្និទ្ធជូន ឯកឧត្តម **ហ្វីលីព កូរ៉ាដ** (Philippe Courad) ប្រធានសភាសហព័ន្ធវ៉ាល់ឡូនី-ព្រុចសែល

-អញ្ជើញរៀបចំពិធីសូត្រមន្ត សុំសេចក្តីសុខ សិរីសួស្តីក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំកុរឯកស័ក ព.ស២៥៦៣ នៅគេហដ្ឋានលេខ២៨៣ ផ្លូវ៦៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ជុំ វង់** លេខាធិការគណៈកម្មការទី៣ និងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៦ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៨ច្បាប់ ។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-អនុញ្ញាតឱ្យឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧រដ្ឋសភា និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងជូនពរក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

-អនុញ្ញាតឱ្យតំណាងធនាគារ FTB ចូលជួបសម្តែងការគួសម និងជូនពរក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

-អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តបួងសួងសុំសេចក្តីសុខ សេចក្តីចម្រើន និងពិសារអាហារសាមគ្គីជាមួយសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

-អញ្ជើញនាំយកទេយ្យទានប្រគេនព្រះសង្ឃ និងចែកអំណោយជូនយាយជី តាជី ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅវត្តប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៤ច្បាប់និងជ្រាបជាព័ត៌មាន ចំនួន១៩ច្បាប់ ។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក:**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកសម័យប្រជុំចំនួន០២លើក ដែលមានរបៀបវារៈ ដូចខាងក្រោម:

១.ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៤

២.ពិនិត្យ និងសម្រេចអំពីការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

៣.ប្រកាសទទួលស្គាល់ឯកឧត្តម **អ៊ឹង លាងហ៊្វ** ជាសមាជិកព្រឹទ្ធសភា នីតិកាលទី៤ នៅមណ្ឌលភូមិភាគទី៧ ជំនួសឯកឧត្តម **ជុំ វង** ដែលបានទទួលមរណភាព

៤.ជ្រើសតាំងលោកជំទាវ **កង សៅរ៉េធន** ជាលេខាធិការគណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ជំនួសឯកឧត្តម **ជុំ វង**

៥.ចាត់តាំងឯកឧត្តម **អ៊ឹង លាងហ៊្វ** ជាសមាជិកក្រុមទី២ នៃក្រុមសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា ជំនួសឯកឧត្តម **ជុំ វង** ។

**៣-សម័យប្រជុំពេញអង្គចំនួន០១លើក**

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១.ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤

២.ស្តាប់របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៤

៣.បោះឆ្នោតជ្រើសរើសបំពេញលោកជំទាវ **កង សៅរ៉េធន** ជាសមាជិកគណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ព្រឹទ្ធសភានីតិកាលទី៤។

**៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមេសានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៤.១- មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញជួបសវនាការ ដើម្បីឈ្វេងយល់អំពីស្ថានភាពអគ្គិសនី រ៉ែ និងប្រេងកាតនៅកម្ពុជា បញ្ហាប្រឈម តម្រូវការ និងដំណោះស្រាយ ក៏ដូចជាទស្សនវិស័យរបស់ក្រសួងចំពោះតម្រូវការកើនឡើងលើការប្រើប្រាស់ថាមពលអគ្គិសនី និងជួបពិភាក្សា

ការងារស្តីពីស្ថានភាពបច្ចុប្បន្ននៃការប្រែក្លាយផ្នែកឌីជីថល និងគោលនយោបាយនៅកម្ពុជា នៅក្រសួងរ៉ែ និងថាមពល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-អញ្ជើញជួបពិភាក្សាការងារដើម្បីឈ្វេងយល់ពីវឌ្ឍនភាពសំខាន់ៗ បញ្ហាប្រឈម និងទិសដៅបន្តរបស់ក្រសួងធម្មការ និងសាសនា ។

**៤.២- មុខងារតំណាង**

-ទទួលពាក្យបណ្តឹងចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០២ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០២ករណី កំពុងពិនិត្យសិក្សាចំនួន០២ករណី បានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០១ករណី និងទទួលឯកសារចម្លងជូនជ្រាបអំពីពាក្យបណ្តឹងចំនួន១២ករណី

-អញ្ជើញចុះឈ្វេងយល់អំពីវឌ្ឍនភាព ចែករំលែក និងផ្តល់ព័ត៌មានជូនក្រុមប្រឹក្សាឃុំស្វាយជ្រុំ ឃុំព្រៃទទឹង ឃុំឃ្នោស ឃុំដូង ឃុំព្រៃពោធិ៍ និងឃុំជ្រៃធំនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង

-អញ្ជើញថ្លែងសន្ទរកថាឆ្លើយតបទៅកាន់ អគ្គលេខាធិការគណៈកម្មការសិទ្ធិអ្នកតំណាងរាស្ត្រនៃ(IPU)អំពីបញ្ហាសិទ្ធិមនុស្សកម្ពុជាក្នុងរង្វង់អ្នកតំណាងរាស្ត្រ និងព្រឹទ្ធសភា

-អញ្ជើញចូលរួមសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៩ស្តីពី ការប្រែក្លាយផ្នែកឌីជីថលឆ្ពោះទៅកាន់ឧស្សាហកម្ម៤.០

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី សភា និងអង្គការតំបន់

-អញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមប្រជុំជាមួយក្រុមសភាជាតិកម្ពុជាប្រើប្រាស់ភាសាបារាំង(APF) សម្រាប់ព្រឹទ្ធសភា ដើម្បីពិភាក្សាអំពី ការពិនិត្យសកម្មភាព(APF) និងការកំណត់គោល-ការណ៍ក្នុងការធ្វើសកម្មភាព

-អញ្ជើញចូលរួមទស្សនា និងផ្តល់យោបល់លើខ្សែវីដេអូព្រឹទ្ធសភាចំនួន០២ខ្សែ រួមមានៈ វីដេអូស្តីពី ឆ្នាំទី១ព្រឹទ្ធសភា នីតិកាលទី៤ និងវឌ្ឍនភាពព្រឹទ្ធសភាក្នុងរយៈពេល២០ឆ្នាំ

-អញ្ជើញចូលរួមប្រជុំក្រុមមិត្តភាពព្រឹទ្ធសភា ជាមួយនឹងសភាសហព័ន្ធរ៉ាឡូនី-ព្រុចសែល ដើម្បីពិនិត្យ និងពិភាក្សាអំពីការត្រៀមទទួលគណៈប្រតិភូសភាសហព័ន្ធរ៉ាឡូនី-ព្រុចសែល ដែលនឹងអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរគម្រប់ខួប១០០ឆ្នាំ នៃការបង្កើតអង្គការអន្តរជាតិខាងការងារ និងខួប៥០ឆ្នាំ នៃសមាជិកភាពកម្ពុជានៅអង្គការអន្តរជាតិខាងការងារ

សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះរាជធានីភ្នំពេញ និងបណ្តាខេត្ត ក្រុង ចំនួន១៥១លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៩លើក។

**៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម ***យ៉ង់ សែម*** ឯកឧត្តម ***ខៀវ*** **មុត** និងឯកឧត្តម **ឈិត គីមយាត** អញ្ជើញចូលរួមមហាសន្និបាត សហភាពអន្តរសភា(IPU) លើកទី១៤០ និងចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក(ASGP) នៅទីក្រុង Doha ប្រទេសកាតា

-ឯកឧត្តម **ឈិត គីមយាត** អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់សភាតំបន់អាស៊ី(APA) នៅទីក្រុងNaryan-Mar នៃសហព័ន្ធរុស្ស៊ី។/

ថ្ងៃ សុក្រ ៧កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ខែឧសភា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ